ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
លេខ: ០៣៤ សបាអ

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

កម្មវត្ថុ: របាយការណ៍នៃកិច្ចប្រជុំរវាង DICO និង IAs ប្រចាំខែមករា

យោង: លិខិតអញ្ជើញលេខ ០២៩០ ពណ-សហអ ចុះថ្ងៃទី ២៦ ខែមករា ២០១២

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរពជូន និង រាយការណ៍ជូន **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា: កាលពីថ្ងៃទី ៣០ មករា ២០១២ DICO បានរៀបចំកិច្ចប្រជុំប្រចាំខែជាមួយភ្នាក់ងារអនុវត្តគម្រោង (Implementing Agencies) ដើម្បីជម្រុញការអនុវត្តន៍គម្រោង TDSP ។ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូននូវចំណុចសំខាន់ៗដូចខាងក្រោម:

ក)- របាយការណ៍វឌ្ឍនៈភាពរបស់គម្រោង TDSP

- ការងារហិរញ្ញវត្ថុ (Finance) ៖ នៅក្នុងត្រីមាសទី៤ យើងបានធ្វើការចំណាយ US 441,071 ស្មើនឹង 67% នៃការចំណាយតាមត្រីមាស
- ការងារលទ្ធកម្ម (Procurement) ៖ គិតមកត្រឹមថ្ងៃទី ៣០ មករា ២០១២ យើងសម្រេចបាន ២៧.៣% នៃចំនួនសរុបរបស់មូលនិធិទាំងមូល
- ផ្សព្វផ្សាយអំពីពង្រឿងនៃការដាក់កំណត់ថ្មី (Benchmarks) របស់ធនាគារពិភពលោកសម្រាប់ឆ្នាំ ២០១២
- ការរៀបចំផែនការបណ្តុះបណ្តាលជាកញ្ចប់សម្រាប់គម្រោងថ្មី

- ការកែសម្រួលការងាររបស់មន្ត្រីទំនាក់ទំនង (Liaison Officer L/O)
- ការងារទំនាក់ទំនង ៖ DICO បានណែនាំមន្ត្រី L/O ឲ្យធ្វើការទំនាក់ទំនង ជាមួយ IAs ដើម្បីរកពេលវេលាជួបជាមួយជំនាញការផ្នែកទំនាក់ទំនង Communication ដើម្បីបំពេញព័ត៌មានចូលក្នុង Factsheet និង Newsletter
- ផ្សព្វផ្សាយអំពីកាលបរិច្ឆេទនៃកិច្ចប្រជុំប្រចាំឆ្នាំរបស់ SSC-TD-TRI, IC និង DICO and IAs meeting សម្រាប់ឆ្នាំ២០១២ ( ភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ I )

ខ)- ផ្នែកលទ្ធកម្ម

ផ្នែកលទ្ធកម្មរបស់ DICO បានបង្ហាញពីវឌ្ឍនភាពរបស់ខ្លួនក្នុងការធ្វើលទ្ធកម្មជូន IAs ដូចជា: អ្នកពិគ្រោះយោបល់ជាតិ និងអន្តរជាតិ (International and National Consultants), សម្ភារៈការិយាល័យ (Office Equipment), និងគ្រឿងសង្ហារឹមការិយាល័យ (Office Furniture) ដែលកញ្ចប់ខ្លះត្រូវបានបញ្ចប់ និងកញ្ចប់ខ្លះទៀតកំពុងបន្ត ។

( ភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ II )

គ)- ផ្នែកហិរញ្ញវត្ថុ

ផ្នែកហិរញ្ញវត្ថុរបស់ DICO បានបង្ហាញពីទឹកប្រាក់សរុប សម្រាប់គម្រោងដែលត្រូវរៀបចំផែនការវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំ ២០១២ និង សំណើគម្រោងជាអាទិភាពប្រចាំឆ្នាំ ២០១២ ព្រមទាំងបានបង្ហាញអំពីរបាយការណ៍របកគំហើញរបស់ផ្នែកហិរញ្ញវត្ថុមានដូចខាងក្រោម:

- មានការយឺតយ៉ាវក្នុងការជម្រះបញ្ជីសាច់ប្រាក់បុរេប្រទាន
- សំណើសុំប្រាក់បុរេប្រទានមានរយៈពេលតិចជាង៥ថ្ងៃ ឬក្នុងរយៈពេលកំពុងអនុវត្តការងារ
- មិនបានលំអិតតម្លៃ និងឯកតានៃទំនិញនិមួយៗក្នុងការទិញសម្ភារៈ និងការថតចម្លងឯកសារ

- វិក្ក័យបត្រមិនបានបរិយាយនូវមុខទំនិញ កាលបរិច្ឆេទ ហត្ថលេខា និងឈ្មោះ អ្នកទិញ និងអ្នកលក់ និងលក់ទៅឲ្យអ្នកណា
- បានជួលឧបករណ៍ប្រើប្រាស់សម្រាប់រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ដែលបានផ្តល់ឲ្យដោយគម្រោងរួចហើយ
- លិខិតស្នើសុំសម្រង់តម្លៃ និងលិខិតបញ្ជាទិញទំនិញ និងសេវាកម្មនានា មិនត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់ធានារាល់ការទូទាត់ចំណាយ
- វិក្ក័យបត្រសម្រាប់ការទូទាត់ចំណាយទិញទំនិញ និងសេវាកម្មនានា គឺជាច្បាប់ចម្លង
- លិខិតបញ្ជាបេសកកម្ម និងទិដ្ឋាការធ្វើដំណើររបស់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមិនបានបំពេញត្រឹមត្រូវ
- ភ្នាក់ងារអនុវត្តបានអនុញ្ញាតឲ្យប្រព័ន្ធផ្សព្វផ្សាយចូលរួម ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានសកម្មភាពរបស់គម្រោង
- ទិញឧបករណ៍ទប់ចរន្តអគ្គិសនីចំនួនប្រាំគ្រឿង ឧបករណ៍ភ្ជាប់អ៊ិនធឺណែត ដោយមិនមានការជូនដំណឹង និងស្នើសុំជាមុនដល់នាយកគម្រោង
- វិក្កយបត្រទូទាត់មានលេខរៀងតាមលំដាប់
- ការចំណាយដែលមានតម្លៃច្រើនជាង២០០ដុល្លារ ចេញពីកញ្ចប់បេឡាសាច់ប្រាក់របស់ខ្លួន
- ការចំណាយទិញ ទឹក តែ កាហ្វេ សម្រាប់ប្រើប្រចាំថ្ងៃត្រូវបានរកឃើញចំពោះ IAs មួយចំនួន
- មន្ត្រីបង្គោលរបស់ IAs មានការផ្លាស់ប្តូរ

( ភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ III )

សន្និដ្ឋានៈ

កិច្ចប្រជុំបានឯកភាពកែសម្រួលនូវរាល់ចំនុចអវិជ្ជមាន ដែលមាននៅក្នុងរបាយការណ៍របកគំហើញរបស់ផ្នែកហិរញ្ញវត្ថុ ដោយខាង DICO នឹងបញ្ជូនបទបង្ហាញនេះទៅដល់ភ្នាក់ងារអនុវត្តន៍ (IAs) ទាំងអស់ក្នុងគោលបំណងឲ្យភ្នាក់ងារអនុវត្ត អនុវត្តន៍ឲ្យបានត្រឹមត្រូវទៅតាមគោលការណ៍ និង និតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោងនៅថ្ងៃខាងមុខ ។

អាស្រ័យហេតុនេះ **សូម ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ កុម្ភៈ ២០១២

**ប្រធាននាយកដ្ឋាន**

ឈៀង ពេជ្រ